# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ: ០៥២ សរាក.ភសក

# សេចក្តីណែនាំ
## ស្តីពី
## វិធានការលើកកម្ពស់ផលិតកម្ម និងធុរកិច្ចស្រូវអង្ករ

នាពេលថ្មីៗនេះ សហគមន៍អឺរ៉ុបបានចេញសេចក្តីប្រកាសព័ត៌មានថា នឹងដាក់វិធានការការពារទីផ្សារដោយចាប់ផ្តើមយកពន្ធលើការនាំចេញអង្កររបស់កម្ពុជា និងប្រទេសមីយ៉ាន់ម៉ា ដែលនាំចូលទៅកាន់សហគមន៍អឺរ៉ុបសម្រាប់រយៈពេល៣ឆ្នាំ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១។ ការយកពន្ធនាំចូលអង្កររបស់កម្ពុជាចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ តទៅ ដោយឆ្នាំដំបូងពន្ធត្រូវបង់មានចំនួន១៧៥អឺរ៉ូក្នុង១តោន ឆ្នាំទី២ត្រូវបង់១៥០អឺរ៉ូក្នុង១តោន និងឆ្នាំទី៣ត្រូវបង់១២៥អឺរ៉ូក្នុង១តោន។ ការដាក់វិធានការការពារទីផ្សារនេះ នឹងធ្វើឱ្យតម្លៃអង្ករកម្ពុជាបង្កើនតម្លៃបន្ថែមទៀតពីលើតម្លៃបច្ចុប្បន្ន ដែលកម្ពុជាលក់នៅលើទីសហគមន៍អឺរ៉ុប។

កន្លងមក នៅឆ្នាំ២០១៧-២០១៨ កម្ពុជាបានផលិតស្រូវចំនួនជាង១០,៥លានតោន និងមានអតិរេកស្បៀងជាអង្ករចំនួន៣,៥៥លានតោន (ឬ៥,៥៦លានតោនស្រូវ) សម្រាប់បម្រើឱ្យការប្រើប្រាស់ឧស្សាហកម្មស្បៀងក្នុងស្រុក និងនាំចេញទៅទីផ្សារអន្តរជាតិ ក្នុងនោះការនាំចេញអង្ករកម្ពុជាទៅសហគមន៍អឺរ៉ុបមានតែចំនួន ២៦៩ពាន់តោន ស្មើនឹង ៧,៥% ប៉ុណ្ណោះ។

ជាមួយគ្នានេះ តម្លៃស្រូវរដូវប្រាំងនៅដើមឆ្នាំ២០១៩នេះ មានការធ្លាក់ចុះបន្តិចបន្តួចធៀបនឹងឆ្នាំកន្លងទៅ ស្របពេលដែលការប្រមូលផលបានមកដល់ និងបរិមាណស្រូវដែលប្រមូលទិញពីកសិករនាពេលនេះមានការថយចុះជាងឆ្នាំកន្លងទៅ ព្រមជាមួយនឹងការបារម្ភពីអ្នកនាំចេញអង្ករ អ្នកប្រមូលទិញស្រូវ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវពីការដាក់វិធានការការពារទីផ្សាររបស់សហគមន៍អឺរ៉ុប ដែលអាចនាំឱ្យមានការទម្លាក់ថ្លៃទិញស្រូវពីកសិករ។

ក្នុងស្ថានភាពនៃការដាក់វិធានការទីផ្សារលើការនាំចូលអង្ករទៅសហគមន៍អឺរ៉ុប ការពង្រឹងនិងពង្រីកសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ពិសេសការកាត់បន្ថយថ្លៃដើមផលិតកម្មគឺជាកត្តាចាំបាច់និងសំខាន់បំផុត។ ម៉្យាងវិញទៀត ដើម្បីលើកកម្ពស់ធុរកិច្ចស្រូវអង្ករ ពិសេសការជួយអន្តរាគមន៍ទប់ស្កាត់សភាពការណ៍ខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចដាក់ចេញនូវវិធានការណែនាំចាំបាច់មួយចំនួនសម្រាប់អនុវត្តបន្ទាន់ដូចខាងក្រោម៖

១. អង្គភាពជំនាញក្រោមឱវាទក្រសួង ត្រូវបន្តការស្រាវជ្រាវបញ្ចេញប្រភេទពូជស្រូវក្រអូបប្រណិត និងផលិតកម្មគ្រាប់ពូជស្រូវក្រអូបសុទ្ធ តាមរយៈការផលិតនៅថ្នាក់សហគមន៍ និងក្រុមកសិករផលិតគ្រាប់ពូជ ធ្វើយ៉ាងណាឱ្យមានគ្រាប់ពូជគ្រប់គ្រាន់ និងតម្លៃសមរម្យ ដើម្បីពង្រីកផលិតកម្មស្រូវក្រអូប។ ជាមួយគ្នានេះ ស្នើវិស័យឯកជនចូលរួមដាក់ទុនវិនិយោគក្នុងការផលិតគ្រាប់ពូជស្រូវក្រអូប ដែលមានគុណភាពខ្ពស់ ស្របតាមស្តង់ដារ និងតម្រូវការទីផ្សារ។

២. ពាក់ព័ន្ធនឹងការកាត់បន្ថយថ្លៃដើមផលិតកម្ម ត្រូវជំរុញឱ្យបានខ្លាំងក្លាបន្ថែមទៀត នូវវិធានការបច្ចេកទេសផលិតកម្មដែលទទួលបានទិន្នផលខ្ពស់ និងចំណាយតិច រួមជាមួយនឹងការអនុវត្តទំនើបភាវូបនីយកម្មកសិកម្ម។ ជាមួយគ្នានេះ ត្រូវបានពិនិត្យកាត់បន្ថយថ្លៃចំណាយលើការធ្វើធូបនកម្ម តាមរយៈការបង្កើន



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

ចំនួនក្រុមហ៊ុន ដែលមានសមត្ថភាពចូលរួមធ្វើការងារនេះឱ្យបានច្រើន មានការប្រកួតប្រជែង និងយកកម្រៃសេវាទាបជាងមុន។ ក្នុងន័យនេះ អគ្គនាយកដ្ឋានកសិកម្ម ត្រូវពិនិត្យសិក្សាឱ្យបានហ្មត់ចត់ និងជំរុញការងារនេះឱ្យបានឆាប់។ ម៉្យាងវិញទៀត ដើម្បីសម្រួលដល់ការនាំចូលជីកសិកម្ម ថ្នាំកសិកម្មឱ្យបានលឿន និងមានប្រសិទ្ធភាពជាងមុន នាយកដ្ឋាននីតិកម្មកសិកម្ម ត្រូវសម្រួលបែបបទការនាំចូលជីកសិកម្ម ថ្នាំកសិកម្ម និងសម្ភារកសិកម្មដទៃទៀតឱ្យកាន់តែប្រសើរជាងមុន។ ជាមួយគ្នានេះ ត្រូវរៀបចំក្រុមការងារបច្ចេកទេសចម្រុះ ចុះពិនិត្យគុណភាពជីគីមីកសិកម្ម និងថ្នាំកសិកម្ម ដើម្បីធានាពីគុណភាពស្របតាមស្តង់ដារកំណត់។

៣. អ្នកប្រមូលទិញស្រូវ ត្រូវបន្តធ្វើការទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីទទួលបានឥណទានប្រមូលទិញស្រូវពីកសិករ សហគមន៍កសិកម្ម និងមិនត្រូវយកហេតុផលនៃការដាក់វិធានការការពារទីផ្សាររបស់សហគមន៍អឺរ៉ុប មកទម្លាក់ថ្លៃទិញស្រូវពីកសិករឡើយ។ ក្រុមហ៊ុននាំចេញអង្ករ ត្រូវពិនិត្យនិងធានាគុណភាពអង្ករក្រអូបឱ្យបានសុទ្ធល្អ មិនត្រូវលាយបន្លំអង្ករប្រភេទផ្សេង ដែលនាំឱ្យអតិថិជនបាត់បង់ជំនឿលើគុណភាពអង្ករក្រអូបកម្ពុជា។

៤. សហព័ន្ធស្រូវអង្ករកម្ពុជា គួរយកចិត្តទុកដាក់ជំរុញឱ្យសមាគមន៍ម៉ាស៊ីនកិនស្រូវ ខិតខំបង្កើនសមត្ថភាពកែច្នៃអង្ករឱ្យមានគុណភាពបន្ថែមទៀត សម្រាប់បម្រើឱ្យទីផ្សារអន្តរជាតិ ពិសេសទីផ្សារប្រទេសចិន ដែលមានរហូតដល់៤០ម៉ឺនតោននាពេលបច្ចុប្បននេះ។ លើសពីនេះទៀត សហព័ន្ធស្រូវអង្ករកម្ពុជា គួរពិគ្រោះយោបល់ជាមួយសមាជិករបស់ខ្លួន ដើម្បីពិនិត្យលើបញ្ហាប្រឈមពីផលប៉ះពាល់នៃការដាក់វិធានការការពារទីផ្សារអង្កររបស់សហគមន៍អឺរ៉ុប រួចលើកសំណើ ឬសំណូមពរមកក្រុមការងារផ្នែកស្រូវ-អង្ករ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ពិនិត្យ និងរកដំណោះស្រាយតាមការចាំបាច់។

ទទួលបាននូវសេចក្តីណែនាំនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ព្រមទាំងអង្គភាពពាក់ព័ន្ធ ត្រូវសហការឱ្យបានល្អជាមួយរដ្ឋបាលរាជធានី-ខេត្ត សមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងម្ចាស់ម៉ាស៊ីនកិនស្រូវ និងអ្នកទិញលក់ស្រូវអង្ករ ចាត់វិធានការជាបន្ទាន់តាមខ្លឹមសារណែនាំខាងលើ សំដៅធានាបាននូវតម្លៃទីផ្សារស្រូវអង្ករ និងបង្កើនសន្ទុះនៃការនាំចេញអង្កររបស់កម្ពុជាទៅកាន់ទីផ្សារអន្តជាតិឱ្យមាននិរន្តរភាព។

ថ្ងៃ ចន្ទ ៥កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ក្រសួងផែនការ
- ក្រសួងពាណិជ្ជកម្ម
- សហព័ន្ធស្រូវអង្ករកម្ពុជា
- រដ្ឋបាលរាជធានី-ខេត្ត
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- ឯកសារ កាលប្បវត្តិ